ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០១ ស.៨.ក

# សេចក្តីថ្លែងការណ៍
# របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ទណ្ឌិត **សម រង្ស៊ី** បាននិយាយក្នុងកិច្ចសម្ភាសន៍ជាមួយលោក មួង ណារ៉េត នៃវេទិកាវិទ្យុអាស៊ីសេរី ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ កាលពីយប់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ដោយប្រើពាក្យសម្តីដ៏អសុរោះមកលើព្រះកិត្តិនាមរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។** នេះគឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតមកលើព្រះចេស្តានៃអង្គព្រះមហាក្សត្រ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាពលរដ្ឋខ្មែរ។

ទីស្តីការគណៈរដ្ឋមន្ត្រី សូមប្រកាសយ៉ាងដាច់អហង្ការថ្កោលទោស ទណ្ឌិត **សម រង្ស៊ី** ដែលតែងតែនិយាយបរិហារផ្ទុយពីការពិត ទម្លាក់កំហុសជាច្រើនលើកច្រើនសាមកលើ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ដោយសារមហិច្ឆតាលោភលន់អំណាច ទណ្ឌិត **សម រង្ស៊ី** ហ៊ានធ្វើអ្វីៗគ្រប់យ៉ាង សូម្បីតែអង្គព្រះមហាក្សត្រជាទីគោរពសក្ការៈ ក៏បុគ្គលរូបនេះហ៊ានប្រមាថដែរ។

ទីស្តីការគណៈរដ្ឋមន្ត្រី ស្នើក្រសួងស្ថាប័នមានសមត្ថកិច្ច ពិសេសស្ថាប័នអយ្យការនិងតុលាការគ្រប់ជាន់ថ្នាក់ ធ្វើការចោទប្រកាន់និងដាក់ទោសជនដែលមានចរិតក្បត់ជាតិនេះ ឱ្យបានតឹងរឹងជាទីបំផុត។

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩